雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.127

# ប្រទេសចិន-ខេត្តយូនណាន

YUNNAN DAILY
PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7455 ថ្ងៃសុក្រ ទី13 ខែ តុលា ឆ្នាំ 2017

## សៀវភៅ "ស៊ីជិនភីងអភិបាលកិច្ចនៃប្រទេសចិន" បកស្រាយអំពីកូនសោមាសសម្រាប់ជំរុញការអភិវឌ្ឍរបស់ប្រទេសចិន

លោក ណាន យីនគូ ជាជំនាញការសិក្សាស្រាវជ្រាវអំពីប្រទេសចិន ដែលមានឈ្មោះល្បីល្បាញនៅក្នុងប្រទេសអាល្លឺម៉ង់ ។ លោកធ្លាប់ទៅរស់នៅខេត្តក្រុងច្រើនក្នុងប្រទេសចិន ហើយបានសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីប្រទេសចិន ។ លោកបានគូសបញ្ជាក់ថា មានជនបរទេសច្រើនមានបំណងចង់ស្វែងយល់អំពីវិធីសាស្ត្រគ្រប់គ្រងប្រទេសចិនរបស់ថ្នាក់ដឹកនាំចិន ។ ទន្ទឹមនឹងនេះ ប្រទេសចិនបានបកប្រែសៀវភៅរបស់លោក ស៊ី ជីនភីង ទៅជាភាសាបរទេសច្រើនមុខ ដើម្បីបកស្រាយបញ្ហានេះជូនពិភពលោក ពិតជានឹងអាចធ្វើឱ្យគេសប្បាយរីករាយជាខ្លាំង ។ ដូច្នេះការបោះពុម្ពផ្សាយសៀវភៅ "ស៊ីជិនភីងអភិបាលកិច្ចនៃប្រទេសចិន" ពិតជាចំពេលល្អណាស់ !"



*សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាចូលរួមក្នុងពិធីសម្ពោធសៀវភៅ ឯកឧត្ដម ស៊ី ជិនភីងអភិបាលកិច្ច នៃប្រទេសចិន" ជាភាសាខ្មែរ កាលពីថ្ងៃទី ១១ខែ មេសា ឆ្នាំ ២០១៧ (រូបថតដោយ Yu Jiangning )*

សៀវភៅនេះចងក្រងដោយការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន ការិយាល័យសិក្សាស្រាវជ្រាវ ឯកសារនៃមជ្ឈិមបក្សកុម្មុយ-នីស្តចិននិងអាជ្ញាធរជាតិភាសាបរទេសប្រទេសចិន ហើយបានបោះពុម្ពផ្សាយជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី អារ៉ាប់ អេស្ប៉ាញ៉ុល ព័រទុយហ្កាល់ អាល្លឺម៉ង់ និងជប៉ុនចំពោះពិភពលោកទាំងមូល នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៤ ។ សៀវភៅនេះបានទទួលការចាប់-អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាជននៃបណ្ដាប្រទេសនានា ដោយបានត្រូវគេប្រសិទ្ធនាមជា "ច្រកសំខាន់សម្រាប់ស្វែងយល់អំពីប្រទេសចិនបច្ចុប្បន្ន" និងជា "កូនសោសម្រាប់ឆ្លើយសំណួរផ្សេងៗអំពីប្រទេសចិន" ។

ក្នុងរយៈពេល៣ឆ្នាំកន្លងទៅនោះ សៀវភៅនេះបានត្រូវបកប្រែជាភាសាបរទេស២១មុខ និងបានបោះពុម្ពផ្សាយ៦,៤២លានក្បាលនៅក្នុងប្រទេស និងតំបន់ចំនួនជាង១៦០លើពិភពលោក ។ ក្នុងនោះ ការបោះពុម្ពផ្សាយនៅក្រៅប្រទេសមានជាងប្រាំសែនក្បាល ដែលបានធ្វើឱ្យសៀវភៅនេះក្លាយទៅជាសៀវភៅរបស់អ្នកដឹកនាំចិន ដែលទទួលបានការចាប់-អារម្មណ៍ខ្លាំងជាងគេ និងមានឥទ្ធិពលខ្លាំងបំផុត បន្ទាប់ពីប្រទេសចិនអនុវត្តន៍គោលនយោបាយកែទម្រង់ និងបើកចំហរៀងមក ។

នៅថ្ងៃទី៨ខែតុលាឆ្នាំ២០១៤ ពិធីបោះពុម្ពផ្សាយសៀវភៅ "អភិបាលកិច្ចនៃប្រទេសចិន" ជាច្រើនភាសាបានប្រារព្ធនៅក្នុងពិព័រណ៍សៀវភៅអន្តរជាតិ Frankfurt ។ លោក Gerhard Schroeder អតីតនាយករដ្ឋមន្ត្រីប្រទេសអាល្លឺម៉ង់បានថ្លែងសុន្ទរកថាក្នុងពិធីបោះពុម្ពផ្សាយនេះថា សៀវភៅ "ស៊ី ជិន-ភីងអភិបាលកិច្ចនៃប្រទេសចិន" បានបកស្រាយអំពីគោលជំហររបស់លោក ស៊ី ជីនភីង និងថ្នាក់ដឹកនាំចិន ។ សៀវភៅនេះនឹងអាចជួយយើងស្វែងយល់អំពីនយោបាយចិន ។ សុបិនចិនដ៏អស្ចារ្យសម្រាប់ស្តារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញ និងគោលដៅនៃការកសាងប្រទេសចិនឱ្យមានលក្ខណៈបើកទូលាយ មានស្ថិរភាព និងមានសេដ្ឋកិច្ចរីកចម្រើន ដែលលើកឡើងក្នុងសៀវភៅនេះ ស្របគ្នាទៅនឹងផលប្រយោជន៍របស់ប្រទេសអឺរ៉ុប ។

ប៉ុន្មានខែមុនសៀវភៅ "ស៊ី ជិនភីងអភិបាលកិច្ចនៃប្រទេសចិន " ជាភាសាអ៊ូសបេគីស្ថានបានត្រូវបោះពុម្ពផ្សាយដោយទីភ្នាក់ងារបោះពុម្ពផ្សាយភាសាបរទេសប្រទេសចិន និងទីភ្នាក់ងារបោះពុម្ពផ្សាយអ៊ូសបេគីស្ថាន ។ លោក Shavkat Mirziyoyev ប្រធានាធិបតីអ៊ូសបេគីស្ថាន បានសរសេរអារម្ភកថាឱ្យសៀវភៅនេះថា សៀវភៅនេះមានសារសំខាន់ណាស់ ដែលនឹងអាចជួយយើងទាំងអស់គ្នាស្វែងយល់អំពីគោលនយោបាយរបស់ប្រទេសចិន ព្រមទាំងខ្លឹមសារ គោលការណ៍ និងគោលលំនាំមូលដ្ឋាននៃកំណែទម្រង់គ្រប់ជ្រុងជ្រោយដែលប្រទេសចិនកំពុងតែដំណើរការអនុវត្តន៍នាពេលបច្ចុប្បន្ន ៕

**ដោយ ស៊ី យីឈី (ដកស្រង់ចេញពីកាសែតប្រជាជនដេលីបោះពុម្ពផ្សាយនៅឯនាយសមុទ្រ)**

## សាកលវិទ្យាល័យយូនណានត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះនៃសាកលវិទ្យាល័យលំដាប់លេខ១លើពិភពលោក



*បន្ទាប់ពីពិធីបើកសម្ពោធ អ្នកចូលរួមក្នុងពិធីនោះបាននាំគ្នាថតរូបថតជាក្រុមជាមួយនឹងរូបសំណាក បណ្ឌិត ខុង ជឺ (រូបថតដោយ Wu Ping )*

***ដោយ អ៉ឹន យូនហ៊ីន***

ពេលថ្មីៗនេះ ក្រសួងអប់រំ ក្រសួងហិរញ្ញវត្ថុ និងគណៈកម្មាធិការអភិវឌ្ឍន៍និងកែទម្រង់ជាតិចិន បានរួមគ្នាប្រកាសបញ្ជីឈ្មោះនៃសាកលវិទ្យា-ល័យលំដាប់លេខ១និងមុខវិជ្ជាឯកទេសលំដាប់លេខ ១ លើពិភព-លោក ។ ក្នុងនោះ សាកលវិទ្យាល័យយូន-ណាន បានត្រូវដាក់បញ្ចូលក្នុងបញ្ជីឈ្មោះ នៃសាកលវិទ្យាល័យលំដាប់លេខ ១ (ចំនួន ៤២) ដែលជាសាកលវិទ្យាល័យតែមួយគត់នៅខេត្តយូន-ណានក្នុងបញ្ជីឈ្មោះទាំងពីរខាងលើ ។

ខេត្តយូនណានត្រូវបានបង្កើតឡើងនៅឆ្នាំ១៩២២ ដែលជាសាកលវិទ្យាល័យចម្រុះមុនគេមួយក្នុងភូមិភាគនិរតីរបស់ប្រទេសចិន ។ បច្ចុប្បន្ន សាកលវិទ្យាល័យយូនណានបានក្លាយទៅជាសាកលវិទ្យាល័យចម្រុះសំខាន់ក្នុងប្រទេសចិន ដែលជាសាកលវិទ្យា-ល័យល្បីឈ្មោះខាងមុខវិជ្ជាសិក្សាស្រាវជ្រាវអំពីជនជាតិ ប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍធនធាន ការថែរក្សាការពារបរិស្ថាន ការសិក្សាស្រាវជ្រាវបញ្ហាតំបន់ព្រំដែន បញ្ហាអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ហើយមានធនធានមនុស្សដ៏សម្បូរ និងមុខវិជ្ជាឯកទេសគ្រប់គ្រាន់ រួមមានអក្សរសាស្ត្រ ប្រវត្តិ-សាស្ត្រ ទស្សនវិជ្ជា សេដ្ឋកិច្ច ច្បាប់ ការអប់រំ រូបសាស្ត្រ និងសិល្បៈជាដើម ៕

## សេដ្ឋកិច្ចចិនបង្ហាញនិន្នាការអភិវឌ្ឍល្អប្រសើរ

នៅថ្ងៃទី២១ ខែកញ្ញា បន្ទាប់ពី Moody's បានកែសម្រួលកម្រិតថ្នាក់នៃការវាយតម្លៃចំពោះជំនឿទុកចិត្តអំពីអធិបតេយ្យភាពរបស់ប្រទេសចិនពី Aa៣ ទៅជា A១ Standard & Poor's ដែលជាអង្គការវាយតម្លៃកម្រិតថ្នាក់ជំនឿទុកចិត្តអន្តរជាតិមួយទៀត បានកែសម្រួលកម្រិតថ្នាក់នៃជំនឿទុកចិត្តអំពីអធិបតេយ្យភាពរបស់ប្រទេសចិនពី AA-ទៅជាA+ នឹងបានសម្លឹងមើលទៅអនាគតថា"មានស្ថិរភាព"។ រឿងនេះបានទទួលការចាប់អារម្មណ៍ពីមនុស្សខ្លះ តែគ្មានប្រតិកម្មខ្លាំងពីទីផ្សារ ទេ ។ ចំពោះការបម្រែបម្រួលតិចតួចនៃការវាយតម្លៃកម្រិតថ្នាក់ចំពោះជំនឿ ទុកចិត្តអំពីប្រទេសចិនបានរក្សាភាព នឹងនរ ដោយគ្មានប្រតិកម្មខ្លាំងទេពីព្រោះសេដ្ឋ-កិច្ចចិនបានបង្ហាញនិន្នាការអភិវឌ្ឍន៍ដ៏ល្អប្រសើរដែលមិនអាច កែប្រែបាន ។

ជាក់ស្តែង លទ្ធផលនៃការទម្លាក់កម្រិតថ្នាក់របស់ប្រទេសចិននេះគ្មានមូលហេតុគ្រប់គ្រាន់នោះទេ ។ Stan-dard & Poor's បានបកស្រាយថា កំណើនឥណទានបានបង្កើនហានិភ័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសចិន។ ប៉ុន្តែដូចអ្នកផងទាំងពួងស្រាប់ជ្រាបហើយថា នៅឆ្នាំ២០១៧ ឥណ-ទានចិនបានកើនឡើងយ៉ាងឆាប់រហ័ស ដោយសារប្រសេចិនខិតខំជំរុញឱ្យបំបាត់ដំបូងគាស់ក្នុងវិស័យហិរញ្ញវត្ថុ ។ នេះបានបង្ហាញឱ្យឃើញពីការដើរឆ្ពោះទៅកាន់សេដ្ឋកិច្ចជាក់ស្តែងរបស់ប្រទេសចិន ហើយក៏បានសឱ្យឃើញថា លទ្ធភាពហានីភ័យហិរញ្ញវត្ថុរបស់ប្រទេសចិនកំពុងធ្លាក់ចុះជាបន្តបន្ទាប់ ។ បើវិភាគចំពោះសេដ្ឋកិច្ចចិន យើងមិនគ្រាន់តែត្រូវយកចិត្តទុកដាក់ចំពោះរយៈពេលខ្លីប៉ុណ្ណោះទេ ថែមទាំងត្រូវសម្លឹងមើលទៅស្ថានភាពរយៈពេលវែងទៀតផង ។ ប្រទេសចិនកំពុងស្ថិតនៅក្នុងដំណាក់កាលផ្លាស់ទម្រង់អភិវឌ្ឍន៍សេដ្ឋកិច្ច ដូច្នេះសេដ្ឋកិច្ចចិននឹងអាចមានការឡើងចុះខ្លះក្នុងរយៈពេលខ្លី តែវាមិនប៉ះពាល់ដល់និន្នាការអភិវឌ្ឍសេដ្ឋកិច្ចដ៏ល្អប្រសើរក្នុងរយៈពេលវែងរបស់ប្រទេសចិនទេ ។ ទន្ទឹមនឹងនេះ គោលនយោបាយអំពីរូបិយវត្ថុ ហិរញ្ញវត្ថុ និងឧស្សាហកម្មនៅមានចន្លោះអភិវឌ្ឍន៍ទូលំទូលាយ ហើយពោរពេញទៅដោយកម្លាំងជំរុញសម្រាប់ធ្វើកំណែទម្រង់ ។ Standard & Poor's បានទម្លាក់កម្រិតថ្នាក់ជំនឿទុកចិត្តអំពីអធិបតេយ្យភាពរបស់ប្រទេសចិន ដោយផ្អែកតែលើបាតុភូតសេដ្ឋកិច្ចរយៈពេលខ្លីរបស់ប្រទេសចិននោះ ពិតជាគ្មានចក្ខុវិស័យវែងឆ្ងាយ ឬក៏ចង់ធ្វើបាបដោយចេតនា ។

ជាយូរយារមកហើយ អង្គការវាយតម្លៃកម្រិតថ្នាក់របស់លោកខាងលិចបានកាន់កាប់សិទ្ធិផ្តាច់មុខក្នុងទីផ្សារប្រឹក្សាយោបល់អំពីការវាយតម្លៃចំពោះជំនឿទុកចិត្ត ដោយតែងតែកោត-សរសើរប្រទេសលោកខាងលិច និងរិះគន់ប្រទេសលោកខាងកើត ដើម្បីទាក់ទាញធនធានឱ្យចូលទៅកាន់ប្រទេសលោកខាងលិច ។ តាមពិតក្រោយពីប្រទេសចិនបានអនុវត្តន៍គោល-នយោបាយកែទម្រង់និងបើកចំហរៀងមកអ្នកនយោបាយអ្នកជំនាញការប្រព័ន្ធផ្សព្វផ្សាយ និងអ្នកគ្រប់គ្រង ក្រុមហ៊ុនអន្តរជាតិជាច្រើនរបស់លោក ខាងលិចបានថ្លែងមតិមូលបង្កាច់ ប្រទេសចិនទេ តែប្រទេសចិនមិនដែលកើតមានបញ្ហាណាមួយដូចគេនិយាយនោះទេ ។

ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃរបស់លោកខាងលិច ក៏ជាការក្រើនរំលឹកចំពោះយើង ដែលនឹងអាចធ្វើឱ្យយើងទាំងអស់គ្នាកាន់តែស្វែងយល់អំពីក្តីលំបាក និងបញ្ហាប្រឈមផ្សេងៗ ។ នេះនឹងអាចធ្វើឱ្យយើងដើរឆ្ពោះទៅមុខកាន់តែវែងឆ្ងាយដោយមានស្ថិរភាព ៕

**ដោយ ចាំង អាវ សេដ្ឋវិទូមកពីផ្នែកហិរញ្ញប្បទាននៃធនាគារអភិវឌ្ឍន៍ជាតិចិន**

**(ដកស្រង់ចេញពីកាសែតប្រជាជនដេលីបោះពុម្ពផ្សាយនៅឯនាយសមុទ្រ)**

## កន្លែងចតរថយន្ត RV ធំជាងគេនៅខេត្តយូនណានបានត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

***ដោយ ជូ ហៃ***

ពេលថ្មីៗនេះ កន្លែងចតរថយន្ត Recreational Vehicle (RV) ធំជាងគេ នៅខេត្តយូនណានបានត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។

កន្លែងចតរថយន្តRV នេះមាន



*រថយន្តRV មួយគ្រឿង នៅកន្លែងចំណតមួយ (រូបថតដោយ: Zhu Hai )*

ឈ្មោះថា "ដំណើរទេសចរ : រមណីយ-ដ្ឋានស្រុកផានម៉ាវ" ដែលមាន ទីតាំងស្ថិតនៅក្នុងភូមិលូពីវស្រុកអាននីងក្រុងគុនមីង។គម្រោងនេះរួមគ្នាបណ្តាក់ទុនវិនិយោគដោយក្រុមហ៊ុនវិនិយោគទេសចរណ៍វប្បធមិខេត្តយូនណាន និងកសិដ្ឋានផានម៉ាវនៅស្រុកអាននីង ។ វាជាគម្រោងរថយន្ត RV ដែលអនុវត្តការសាងសង់តាមស្តង់ដារអន្តរជាតិ និងមានហេដ្ឋារចនាសម្ព័ន្ធ គ្រប់គ្រាន់ ។ កន្លែងចតរថយន្ត RV នេះ មានផ្ទៃក្រឡាជាង១៣០ហិកតា ។ សព្វថ្ងៃ មានកន្លែងចតរថយន្ត RV ចំនួន៥០ និងមានប្រព័ន្ធផ្គត់ផ្គង់ទឹកនិងអគ្គិសនីដោយស្វ័យប្រវត្តិចំនួនជាង ២០ ។

កន្លែងនេះ គឺជារមណីយដ្ឋានទេសចរណ៍មួយដែលសម្បូរទៅដោយធនធានទេសចរណ៍ និងកសិកម្ម ព្រមទាំងមានទេសភាពធម្មជាតិដ៏ស្រស់ស្អាត ហើយនឹងបន្តអភិវឌ្ឍតាមរូបភាពថ្មី ដែលច្របាច់បញ្ចូលគ្នានូវវិស័យកសិកម្ម ការកាត់បន្ថយភាពក្រីក្រ ការអប់រំអំពីប្រព័ន្ធអេកូឡូស៊ី និងទេស-ចរណ៍វប្បធម៌ ៕

## ថ្នាក់ខុងជឺនៃសាកលវិទ្យាល័យបើកចំហខេត្តយូនណានសម្ពោធជាផ្លូវការ

***ដោយ អ៊ូ ភីង***

ពេលថ្មីៗនេះ ថ្នាក់ខុងជឺនៃសាកលវិទ្យាល័យបើកចំហខេត្តយូន-ណាន និងថ្នាក់ខុងជឺចំនួន ៥ នៅក្រុងឈូជាំង បានត្រូវបើកសម្ពោធជាផ្លូវការនៅសាកលវិទ្យាល័យបើកចំហខេត្តយូនណាន ។ នៅដើមឆ្នាំ ២០១៤ មូលនិធិខុងជឺប្រទេសចិនបានចាប់ផ្តើមអនុវត្តន៍គម្រោង"ថ្នាក់ខុងជឺ" ដើម្បីផ្សព្វផ្សាយពីវប្បធម៌ប្រពៃណីចិន ។ នៅឆ្នាំ ២០១៦ សាកលវិទ្យាល័យបើកចំហខេត្តយូនណានបានលើកសំណើជូនមូលនិធិខុងជឺប្រទេសចិន ដោយឈរលើឧត្តមភាពនៃការអប់រំភាសាចិនរបស់ខ្លួនទាំងក្នុងថ្នាក់បង្រៀន និងតាមបណ្តាញអ៊ីនធើណេត ហើយបានទទួលការអនុញ្ញាតឱ្យបង្កើតថ្នាក់ខុងជឺ ។ នៅខែមករាឆ្នាំ ២០១៧ មូលនិធិខុងជឺប្រទេសចិនបានផ្តល់ស្លាកឈ្មោះនៃថ្នាក់ខុងជឺដល់សាកលវិទ្យាល័យបើកចំហខេត្តយូនណាន ។

សព្វថ្ងៃ ថ្នាក់ខុងជឺនៃសាកលវិទ្យាល័យបើកចំហខេត្តយូនណានបានរៀបចំសកម្មភាពមួយចំនួនធំ ដូចជាបង្ហាត់ក្បាច់គុនថៃជី និងបណ្តុះបណ្តាលសិល្បៈហូបតែជាដើម ៕